**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារជាន់ខ្ពស់ប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាខេត្ត-ក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៩២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១.-** ត្រូវបានបង្កើតក្រុមការងារជាន់ខ្ពស់ប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាខេត្ត-ក្រុង ដើម្បីសំរបសំរួលការងារ អនុវត្តគំរោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធពត៌មានជាតិ ក្នុងក្របខណ្ឌជំនួយមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច ពីសាធារណរដ្ឋកូរ៉េជាមួយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ ពត៌មានវិទ្យា ក្រុមការងារបច្ចេកទេសប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាខេត្ត-ក្រុង និងបណ្តាអង្គភាព ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣- ឯកឧត្តម **ឡុង ណារ៉ាត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤- ឯកឧត្តម **សូខ ម៉េងសា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម **តូ លីឌុឡ** | អគ្គលេខាធិការ NiDA | សមាជិក |
| ៦- អគ្គនាយក | អគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- អគ្គនាយក | អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- អគ្គនាយក | អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- អភិបាល | គ្រប់ខេត្ត_ក្រុងពាក់ព័ន្ធ | សមាជិក |
| ១០_ស្នងការ | នគរបាលគ្រប់ខេត្ត_ក្រុងពាក់ព័ន្ធ | សមាជិក |

**មាត្រា២.** ក្រុមការងារជាន់ខ្ពស់ប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាខេត្ត-ក្រុង ដំណើរការប្រជុំការងារ ក្រោមការដឹកនាំរបស់ប្រធាន ឬសមាជិកណាម្នាក់ដែលប្រធានប្រគល់សិទ្ធិឱ្យ។

**មាត្រា៣.** ក្នុងករណីចាំបាច់ ប្រធានក្រុមការងារជាន់ខ្ពស់ប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាខេត្ត-ក្រុង អាចលើកសំណើបំពេញបន្ថែមសមាជិកតាមតំរូវការជាក់ស្តែង។

**មាត្រា៤.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម អស់លោកដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ